# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 1013

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

ផ្នែក ក

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

១. ឈ្មោះគម្រោង : ការរៀបចំខ្សែរត់ និងចំណតរង់ចាំរថយន្តក្រុង នៅតាមផ្លូវជាតិលេខ១.២.៣.៤.៥.៦ និងលេខ២១

២. កាលបរិច្ឆេទគម្រោង

| | |
|---|---|
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | 01/01/26 |
| កាលបរិច្ឆេទបញ្ចប់គម្រោង | 31/12/28 |
| ៣. ចំណាយគម្រោងសរុប | $3,724,000 |
| ៤. ស្ថាប័នទទួលខុសត្រូវ | ក្រសួងសាធារណការ និងដឹកជញ្ជូន |
| RESPONSIBLE UNIT | Department of Urban Public Transport |
| អង្គភាពទទួលខុសត្រូវ | នាយកដ្ឋានដឹកជញ្ជូនសាធារណៈក្រុង |
| ៥. ស្ថានភាពគម្រោង | គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ. |

ព័ត៌មានលម្អិតអំពីគម្រោង

| | |
|---|---|
| ៦. ប្រភេទគម្រោង ៖ | គម្រោងវិនិយោគជាទុន |
| ៧. ប្រភពហិរញ្ញប្បទាន៖ | ស្វែងរកម្ចាស់ជំនួយ |

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

មុំទី២- ការលើកកម្ពស់ការតភ្ជាប់ និងការបង្កើនប្រសិទ្ធភាពនៃវិស័យដឹកជញ្ជូន និង ឡូជីស្ទីក, វិស័យថាមពល, វិស័យទឹកស្អាត និងវិស័យឌីជីថល

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

-រៀបចំផែនការ ចុះពិនិត្យអង្កេតស្ថានភាពជាក់ស្តែង និងសិក្សាគូរប្លង់លំអិត
-កៀងគរប្រតិបត្តិករ ឬក្រុមហ៊ុនធ្វើអាជីវកម្មដឹកជញ្ជូនអ្នកដំណើរសាធារណៈតាមរថយន្តក្រុង
-ផ្សព្វផ្សាយ បើកវគ្គសិក្ខាសាលា និងប្រឹក្សាជំនាញបច្ចេកទេស

## ១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍ វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៏វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ ? មិនគាំទ្រ

១១. វិស័យ ( សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

ការដឹកជញ្ជូន Roads

១២. ទីតាំងអនុវត្តគម្រោង (ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង)

តាកែវ, ព្រៃវែង, កំពង់ស្ពឺ, កំពត, កំពង់ចាម, រាជធានីភ្នំពេញ, កែប, កណ្ដាល, កំពង់ឆ្នាំង, ស្វាយរៀង,

១៣. គោលបំណងរបស់គម្រោង (ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង)

គម្រោងរៀបចំខ្សែរត់ និងចំណតរង់ចាំរថយន្តក្រុងតាមផ្លូវជាតិលេខ១.២.៣.៤.៥.៦ និងលេខ២១ មានគោលបំណងដោះស្រាយស្ថានភាពចរាចរណ៍កកស្ទះជារៀងរាល់ថ្ងៃនៅតាមបណ្ដាផ្លូវជាតិសំខាន់ៗ ដែលមានលំហូរចរាចរណ៍ចេញចូលរាជធានីភ្នំពេញ និងពុំមានមធ្យោបាយដឹកជញ្ជូនសាធារណៈតាមរថយន្តក្រុងនៅឡើយ។ ជាក់ស្ដែងការដឹកជញ្ជូនសាធារណៈតាមរថយន្តក្រុងផ្ដល់អត្ថប្រយោជន៍ដល់ប្រជាពលរដ្ឋជាច្រើនដូចជា៖

- ផ្ដល់ភាពងាយស្រួលក្នុងការធ្វើដំណើររបស់ប្រជាពលរដ្ឋ
- មានសុវត្ថិភាព និងផាសុកភាពនៅពេលធ្វើដំណើរទៅមក
- សន្សំសំចៃពេលវេលា និងថវិកា
- កាត់បន្ថយការប្រើប្រាស់មធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួន
- កាត់បន្ថយភាពកកស្ទះ និងគ្រោះថ្នាក់ចរាចរណ៍
- កាត់បន្ថយការប្រើប្រាស់ប្រេងឥន្ធនៈ
- កាត់បន្ថយឧស្ម័នបំពុលបរិស្ថាន
- កាត់បន្ថយផលប៉ះពាល់សុខុមាលភាពប្រជាពលរដ្ឋ
- បង្កើនភាពស៊ីវិល័យក្នុងការទាក់ទាញភ្ញៀវទេសចរណ៍។

១៤. ការពិពណ៌នាអំពីគម្រោង (ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង)

គម្រោងរៀបចំខ្សែរត់ និងចំណតរង់ចាំរថយន្តក្រុងតាមផ្លូវជាតិលេខ១.២.៣.៤.៥.៦ និងលេខ២១ គ្រោង ធ្វើជាប្រព័ន្ធខ្សែរត់ និងរៀបចំចំណតរង់ចាំរថយន្តក្រុងមានចំនួនសរុប ៤៥០កន្លែង ដោយត្រូវសាងសង់រួមមាន៖

-សាងសង់ជម្រករង់ចាំសម្រាប់អ្នកដំណើរធ្វើអំពីដែកប្រក់ដំបូល ចាក់បេតុងកម្រាលបាត បំពាក់កៅអីអង្គុយ និងតម្លើងស្លាកសញ្ញាសម្គាល់ចំណតរថយន្តក្រុង

-ស្ថាបនាផ្លូវចូលចតរបស់រថយន្តក្រុង(Bus Bay) ធ្វើអំពីបេតុងអាម៉េដូចមានគំនូសប្លង់ភ្ជាប់មកជាមួយ។

១៥. យុត្តិកម្មលើគម្រោង (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

- មិនទាន់មានចំណតរង់ចាំនៅតាមផ្លូវជាតិដែលចាប់បន្តពីរាជធានីភ្នំពេញទៅតាមបណ្ដាខេត្តក្រុងនានា
- ផ្ដល់ឱ្យប្រជាពលរដ្ឋមកប្រើសេវារថយន្តក្រុងដើម្បីកាត់បន្ថយការប្រើប្រាស់យានយន្តផ្ទាល់ខ្លួន
- កាត់បន្ថយការកកស្ទះចរាចរ និងគ្រោះថ្នាក់ចរាចរនៅតាមផ្លូវជាតិ
- បង្កើនបរិស្ថានល្អ និងមានសោភណភាពល្អ

១៦. ផលប្រយោជន៍របស់គម្រោង (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

-អ្នកដំណើរទាំងអស់ធ្វើដំណើរប្រកបទៅដោយសុវត្ថិភាព និងផាសុកភាព ជាពិសេសបុគ្គលិក កម្មករ សិស្ស និស្សិត ចាស់ជរា ...។ល។

-ផ្ដល់ភាពរីកចំរើនដល់រដ្ឋាភិបាល ក្រុមហ៊ុន អ្នកវិនិយោគទុន និងដៃគូអភិវឌ្ឍន៍នានា

-ទទួលបានដំណោះស្រាយនៃការស្ទះចរាចរប្រកបដោយចីរភាព

១៧. ការសិក្សាសមិទ្ធិលទ្ធភាព

| | |
|---|---|
| តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? | មាន |
| ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? | ត្រូវបានរៀបចំ |

១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

**-ជួយធ្វើឱ្យបរិស្ថានបានល្អ និងជួយកាត់បន្ថយសារធាតុពុលដែលបណ្តាលមកពីយានយន្ត។**
**-ជួយកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ តាមរយៈការប្រើប្រាស់សេវារថយន្តក្រុង។**

**១៩. ការប្រែប្រួល អាកាសធាតុ**

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **គ្មាន**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹង ការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួល អាកាសធាតុ |
|---|---|---|
| **១៤. ការកាត់បន្ថយការបញ្ចេញឧស្ម័ន** | 50 | **ទាក់ទងមធ្យម** |

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **គ្មាន**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

**-គម្រោងនេះ ជួយជ្រោមជ្រែងដល់បុរស និងស្ត្រីទាំងអស់**
**-ជួយដល់ស្ត្រីក្នុងការធ្វើដំណើរដោយសុវត្ថិភាព តួយ៉ាងដូចជាស្ត្រីមានផ្ទៃពោះ ជាដើម។**

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

**-មានមន្ត្រីជំនាញ និងមានបទពិសោធន៍ច្រើនឆ្នាំ**
**-មានកិច្ចសហការពីជំនាញការបរទេស អង្គការក្នុងស្រុកនិងក្រៅស្រុក និងដៃគូវិនិយោគ**

**២៣. ស្ថានភាពនៃការអនុវត្តគម្រោង** (ពិពណ៌នាសង្ខេបអំពីវឌ្ឍនភាពរបស់គម្រោងនិងបង្ហាញអំពីភាពប្រឈមនានា ដែល បណ្តាលឲ្យមាន ការព្យាពេលក្នុងការអនុវត្តគម្រោង។)

**-មិនទាន់បានអនុវត្តគម្រោងនៅឡើយ**
**-គម្រោងនេះ កំពុងធ្វើការសិក្សាលំអិត**

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

10

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

**បច្ចុប្បន្នមានដៃគូដែលជាក្រុមហ៊ុនកូរ៉េ បានមកចុះសិក្សាពីលទ្ធភាពធ្វើអាជីវកម្មដឹកជញ្ជូនអ្នកដំណើរ តាមរថយន្តក្រុងនៅតាមផ្លូវជាតិលេខ៤ ផ្លូវជាតិលេខ២ រួចហើយ។**

# ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2024 | | 2025 | 2026 | 2027 | 2028 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2026-2028 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 0.0 | 0.0 | 0.0 | 69.4 | 75.2 | 71.0 | 215.6 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 0.0 | 0.0 | 0.0 | 57.6 | 69.1 | 63.4 | 190.1 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 0.0 | 0.0 | 0.0 | 8.5 | 1.5 | 1.8 | 11.8 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 3.3 | 4.6 | 5.8 | 13.7 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 0.0 | 0.0 | 0.0 | 1,267.7 | 1,552.8 | 688.1 | 3,508.6 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 0.0 | 0.0 | 0.0 | 1,149.8 | 1,478.3 | 657.0 | 3,285.1 | 0.0 |
| សេវាទីប្រឹក្សា | 0.0 | 0.0 | 0.0 | 34.5 | 44.3 | 19.7 | 98.5 | 0.0 |
| ទព្វសម្ភារៈ | 0.0 | 0.0 | 0.0 | 58.0 | 6.0 | 0.0 | 64.0 | 0.0 |
| ការបណ្តុះបណ្តាល | 0.0 | 0.0 | 0.0 | 2.4 | 2.0 | 1.5 | 5.9 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 23.0 | 22.2 | 9.9 | 55.1 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 0.0 | 0.0 | 0.0 | 1,337.1 | 1,628.0 | 759.1 | 3,724.2 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2024 | | 2025 | 2026 | 2027 | 2028 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2026-2028 | |
| | | | | | | | | |
| ចំណូលពីគម្រោង | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ថវិកាជាតិ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម | 0.0 | 0.0 | 0.0 | 1,337.1 | 1,628.0 | 759.1 | 3,724.2 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទៈ